ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦០៦ សហវ.ពន

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញ ព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញ សារាចរលេខ ០៦ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រង និងការកែទម្រង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

- បានឃើញ ប្រកាសលេខ ៥០១ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីការកំណត់តម្លៃគិតពន្ធប្រថាប់ត្រា
- យោងតាមការងារចំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា ។

**សំរេច**

**ប្រការ១** : ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូន ដោយអនុវត្តសាលក្រមរបស់តុលាការដែលបានសំរេចរឹបអូសអចលនទ្រព្យ ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូន របស់កូនបំណុលសំរាប់ធ្វើការទូទាត់សងបំណុល គឺមានលក្ខណៈដូចគ្នានិងការទិញលក់ដែរ ម្ចាស់បំណុលជាអ្នកបានទទួលកម្មសិទ្ធិ បានទទួលសិទ្ធិ ត្រូវបង់ពន្ធប្រថាប់ត្រា ។

**ប្រការ២** : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៣

**គាត ឈន់**

**ចម្លងជូន** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ